## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ឆ្នាំទី ៧ លេខ ១៣ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

[illegible]

[illegible]

[illegible]

# ភូមិវិទ្យា

[illegible]

[illegible]

[illegible]

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០២-៤-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៧ បន្ទូរបន្ថយរយៈពេលរងទោសអោយជនទណ្ឌិត ៦២៨

០២-៤-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៨ តែងតាំងលោកជំទាវ ស៊ុន សាធឿន ជាអនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦២៩

៨-៤-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៩ បន្ថយរយៈពេលរងទោសអោយជនទណ្ឌិត ៦៣០


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


៦-៤-១៩៩៩ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក ៦៣២

០១-៤-១៩៩៩ -អនុក្រឹត្យលេខ ៩០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ៦៤៧

០១-៤-១៩៩៩ -អនុក្រឹត្យលេខ ៩១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៤៨

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ ៦៤៩

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥១

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥២

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៣

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៣

៧-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៤

៨-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៥

៨-៤-១៩៩៩ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥៩


### ២-សេចក្តីសំរេច


០២-៤-១៩៩៩ -សេចក្តីសំរេចលេខ ២៦ សសរ ស្តីពីការបង្កើតគណៈកម្មការ ចំរុះដើម្បីដោះស្រាយបញ្ហាអ្នកស្នាក់នៅក្នុងអន្តេវាសិកដ្ឋានពេទ្យ ៦៥៦

| | | |
|---|---|---|
| ០២-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ២៧ សសរ ស្ដីពីការបញ្ឈប់សុពលភាពលិខិតអនុញ្ញាតអោយយកអាវុធតាមខ្លួន | ៦៥៨ |
| ០២-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ២៨ សសរ ស្ដីពីការបង្កើតគណៈកម្មការ ដកហូតអាវុធជាតិផ្ទុះ | ៦៥៩ |
| ៥-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ២៩ សសរ ស្ដីពីការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវ អំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍ តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ | ៦៦១ |
| ៥-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ៣០ សសរ ស្ដីពីការបន្ថែមសមាសភាព ក្នុងគណៈកម្មការដកហូតអាវុធជាតិផ្ទុះ | ៦៦៣ |
| ៥-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ៣១ សសរ ស្ដីពីការបង្កើតគណៈកម្មការជួសជុល បូរីកីឡា | ៦៦៤ |
| ៨-៤-១៩៩៩ | -សេចក្ដីសំរេចលេខ ៣២ សសរ ស្ដីពីការបន្ថែមសមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា | ៦៦៥ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

★★★

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ទ្រង់យល់ក្រឹត្យ លេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ១៩៨៨

**ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបន្ធូរបន្ថយទោសរយៈពេល ១២ ខែ អោយទណ្ឌិតចំនួន ០១ នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស :

-ទណ្ឌិតឈ្មោះ សំ សឡឹម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់អស់ជីវិតតាមអំណាចសាលក្រមលេខ ៣៥ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់តុលាការយោធា ។

មាត្រា ២ ._ ត្រូវបានបន្ធូរបន្ថយទោសរយៈពេល ៦ខែ អោយទណ្ឌិតចំនួន០១នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស :

-ទណ្ឌិតឈ្មោះ ហ៊ិន ហេង ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការយោធា ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ មានអនុភាព អនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៤ ._ ទីស្តីការគណៈរដ្ឋមន្ត្រី -រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ តុលាការយោធា ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះអោយបានជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងលោកជំទាវ ស៊ុន សារឿន ជាអនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៧៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ.ចុះថ្ងៃទី២០-៦-៨៨

**ទ្រង់ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបន្ថយរយៈពេលទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ១៨នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចរាយនាមខាងក្រោមនេះ ៖

១-ទណ្ឌិតឈ្មោះ ខេង ភាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៥ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកោះកុង ។

២-ទណ្ឌិតឈ្មោះ សុ ម៉ៅ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី១៩-០៤-៩៦ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

៣-ទណ្ឌិតឈ្មោះ ស៊ាន សៃ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៥ ចុះថ្ងៃទី៩-៦-៩៥ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

៤-ទណ្ឌិតឈ្មោះ ឌិម សេក ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី១៥-០៣-៩៦ របស់តុលាការខេត្តក្រចេះ ។

៥-ទណ្ឌិតឈ្មោះ ប្រាក់ ហឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី១៣-៨-៩៦ របស់តុលាការខេត្តក្រចេះ ។

៦-ទណ្ឌិតឈ្មោះ អ៊ី នី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី៦-៨-៩៦ របស់តុលាការខេត្តក្រចេះ ។

៧-ទណ្ឌិតឈ្មោះ ស៊ិន សុផេង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី៦-៨-៩៦ របស់តុលាការខេត្តក្រចេះ ។

៨-ទណ្ឌិតឈ្មោះ ហោ ហុង ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី៦-៨-៩៦ របស់តុលាការខេត្តក្រចេះ ។

៩-ទណ្ឌិតឈ្មោះ សៀង ស្រ៊ីម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី៦-៨-៩៦ របស់តុលាការខេត្តក្រចេះ ។

១០-ទណ្ឌិតឈ្មោះ ហ៊ុល ហុខ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាច សាលក្រមលេខ ៧៦ ចុះថ្ងៃទី៧-១២-៩៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

១១-ទណ្ឌិតឈ្មោះ សាន សុផា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៥ ចុះថ្ងៃទី៣-៨-៩៦ របស់តុលាការខេត្តកំពង់ឆ្នាំង ។

១២-ទណ្ឌិតឈ្មោះ ឈាន នួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលក្រមលេខ ០៧ " ត " ចុះថ្ងៃទី៨-៤-៩៨ របស់តុលាការខេត្តកណ្តាល ។

១៣-ទណ្ឌិតឈ្មោះ ជ័យ ចន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ៣៥ " ភ " ចុះថ្ងៃទី១៩-៩-៩៧ របស់តុលាការខេត្តកណ្តាល ។

១៤-ទណ្ឌិតឈ្មោះ លី គឹមសាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលដីកាលេខ ២៦៧ ចុះថ្ងៃទី១៦-១២-៩៨ របស់សាលាឧទ្ធរណ៍ក្រុងភ្នំពេញ ។

១៥-ទណ្ឌិតឈ្មោះ ជ័យ សារឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ ៦ខែតាម អំណាចសាលក្រមលេខ ៩៨ ចុះថ្ងៃទី១៨-៧-៩៨ របស់តុលាការខេត្តបាត់ដំបង ។

១៦-ទណ្ឌិតឈ្មោះ ឈឿន សុគុណ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាម អំណាចសាលក្រមលេខ ១៩៨ ចុះថ្ងៃទី២១-០២-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៧-ទណ្ឌិតឈ្មោះ ពៅ សារិន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាច សាលក្រមលេខ ២៥៦ ចុះថ្ងៃទី១៦-៩-៩៥ របស់តុលាការខេត្តបាត់ដំបង ។

១៨-ទណ្ឌិតឈ្មោះ សេម ឃួម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ៦៤ ចុះថ្ងៃទី៥-៣-៩៦ របស់តុលាការខេត្តបាត់ដំបង ។

មាត្រា ២ .- ត្រូវលើកលែងទោសអោយទណ្ឌិតចំនួន ៥ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរង ទោសក្នុងពន្ធនាគារកន្លងមកដូចរាយឈ្មោះខាងក្រោមនេះ ៖

១-ទណ្ឌិតឈ្មោះ កៅ ខួន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាល ក្រមលេខ ៥២ " ខ " ចុះថ្ងៃទី២៥-៧-៩៥ របស់តុលាការក្រុងភ្នំពេញ ។

២-ទណ្ឌិតឈ្មោះ គៀង យ៉ុងញូ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាច សាលក្រមលេខ ០១ " ខ " ចុះថ្ងៃទី១២-០១-៩៥ របស់តុលាការក្រុងភ្នំពេញ ។

៣-ទណ្ឌិតឈ្មោះ កែ ហឿន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាល ក្រមលេខ ០២ ចុះថ្ងៃទី២៣-១០-៩៨ របស់តុលាការខេត្តកំពង់ធំ ។

៤-ទណ្ឌិតឈ្មោះ ម៉ុត ណាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ តាមអំណាចសាល ក្រមលេខ ៣៥ ចុះថ្ងៃទី១២-១០-៩៨ របស់តុលាការក្រុងព្រះសីហនុ ។

៥-ទណ្ឌិតឈ្មោះ សោម ផន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ តាមអំណាចសាល ក្រមលេខ ១២០ ចុះថ្ងៃទី៣-១០-៩៧ របស់តុលាការខេត្តបាត់ដំបង ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៤ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងវប្បធម៌ ក្រសួងមហាផ្ទៃ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៧ អនក្រ.បក

### ស្តីពីការត្រួតពិនិត្យការបំពុលទឹក

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩

**សំរេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

មាត្រា ១ ._ អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

មាត្រា ២ ._ អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្ក អោយមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

មាត្រា ៣ ._ និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក- " **តំបន់ទឹកសាធារណៈ** " : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ- " **ប្រភពបំពុល** " គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូនរឺតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញ សំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ។

គ-" **សំណល់រាវ** " : គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ- " **ទឹកលូ** " : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ។

ង- " **សំណល់រឹង** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច- " **សំរាម** " : គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ- " **សារធាតុបំពុល** " : គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើអោយមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើអោយប្រែប្រួលនូវលក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ- " **បរិមាណសារធាតុបំពុល** " : គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ- " **សារធាតុប្រកបដោយគ្រោះថ្នាក់** " : គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់ និងសារធាតុប្រកបដោយគ្រោះថ្នាក់

មាត្រា ៤ ._ ការិកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

មាត្រា ៥ ._ ក្នុងករណីចាំបាច់ និងត្រូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចម្រុះ ក្រសួងបរិស្ថាន ត្រូវរៀបចំការិតស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែកសំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ការិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ -មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៦ ._ ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមការិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

មាត្រា ៧ ._ ក្រសួងបរិស្ថាន ត្រូវរៀបចំការិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ ។

ការិតកំណត់ស្តង់ដារបរិមាណសាធារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៧ នៃអនុក្រឹត្យនេះ ត្រូវកំនត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

មាត្រា ៨ ._ ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹកសាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំអោយមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

មាត្រា ៩ ._ ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣
## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

មាត្រា ១០ ._ ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១ ._** ប្រភេទនៃប្រភពបំពុល ដែលត្រូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក- ប្រភពបំពុលប្រភេទថ្នាក់ទី១ ត្រូវអោយមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ- ប្រភពបំពុលប្រភេទថ្នាក់ទី ២ ចាំបាច់ត្រូវឲ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២ ._** ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងរោងចក្រថ្មី និងទាំងរោងចក្រកំពុងដំណើរការ លើកលែងតែរោងចក្រប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រោងចក្រនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការត្រូវអោយសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣ ._** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ ថ្ងៃសំរាប់រោងចក្រនៅភ្នំពេញ និង ៦០ ថ្ងៃសំរាប់រោងចក្រនៅតាមខេត្តក្រុងនៃការចាប់ផ្តើមដំណើរការ សំរាប់ប្រភពបំពុលដែលជារោងចក្រថ្មី ។
- អោយបានក្នុងរយៈពេល ៣០ ថ្ងៃសំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤ ._** លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃនឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំណត់ដោយក្រសួងបរិស្ថាន ។

**មាត្រា ១៥ ._** ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ ថ្ងៃនៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦ ._** បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅ

ទីដទៃ ត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំណុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬ ការកាន់បន្តរបស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬ កាន់កាប់បន្តនោះ ។

មាត្រា ១៧ ._ លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅអោយម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

មាត្រា ១៨ ._ ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ១៩ ._ ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

មាត្រា ២០ ._ ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

មាត្រា ២១ ._ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-ចំណូលនេះត្រូវបញ្ចូនទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

មាត្រា ២២ ._ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

មាត្រា ២៣ ._ ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវ :

ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាត និងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឲ្យឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែង

ក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងការិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ-មានសំភារៈនិងមធ្យោបាយគ្រប់គ្រាន់សំរាប់រាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈ នៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់ទ្រូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុល ដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវផ្ញើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ ខែម្តង ។

**មាត្រា ២៤ .**_ ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅនឹងការិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅនឹងការិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឲ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះ ធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឲ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

**មាត្រា ២៥ .**_ ការិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

ការិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់ការពារសុខភាពសាធារណៈ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៦ .**_ ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំ ពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ២៧ .**_ ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៨ ._ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៩ ._ ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

មាត្រា ៣០ ._ នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធី ដូចមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម របស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុល ដើម្បីធ្វើអធិការកិច្ច យកគំរូតាងឬ ពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ នឹងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឲ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើប្រាស់ជាវត្ថុតាង។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលមួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន។

មាត្រា ៣១ ._ ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កអោយមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

មាត្រា ៣២ ._ ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

មាត្រា ៣៣ ._ ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថាន ត្រូវ :

ក-ធ្វើកំណត់....ហេតុប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-កំណត់....ប្រមូលនិងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ ទៅដល់សុខភាពមនុស្ស សត្វឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

មាត្រា ៣៤ ._ ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ៣៥ ._ កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តខុស ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តនូវវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

មាត្រា ៣៦ ._ មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬឃុបឃិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល នឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានបញ្ញត្តិ

មាត្រា ៣៧ ._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៩ ._ អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

***

១- សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុ សរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក

២- សមាសធាតុសរីរាង្គផូស្វរ

៣- សមាសធាតុសរីរាង្គទីន

៤- សារធាតុដែលបង្កអោយមានជំងឺមហារីក

៥- បារត និងសមាសធាតុរបស់វា

៦- កាត់ម្ញូម និងសមាសធាតុរបស់វា

៧- សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃ សមាសធាតុប្រេងឆៅ

៨- សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក ឬលិចក្នុងទឹក ហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩- សារធាតុវិទ្យុសកម្ម

១០- លោហៈនិងសមាសធាតុ របស់វាដូចជា :

| | | | | | | | |
|---|---|---|---|---|---|---|---|
| សង្កសី | ( Zn ) | សេលេនីយ៉ូម | ( Se ) | សំណប៉ាហាំង | ( Sn ) | វ៉ាណាដ្យូម | ( V ) |
| ទង់ដែង | ( Cu ) | អាសេនិច | ( As ) | បារីយ៉ូម | ( Ba ) | កូបាល់ | ( Co ) |
| នីកែល | ( Ni ) | អង់ទីម៉ូនី | ( Sb ) | បេរីលីយ៉ូម | ( Be ) | តាល់យ៉ូម | ( Tl ) |
| ក្រូម | ( Cr ) | ម៉ូលីបដែន | ( Mo ) | បរ | ( B ) | តេលុយរីយ៉ូម | ( Te ) |
| សំណ | ( Pb ) | ទីតានីយ៉ូម | ( Ti ) | អ៊ុយរ៉ាញ៉ូម | ( U ) | ប្រាក់ | ( Ag ) |

១១- សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២- សមាសធាតុអសរីរាង្គផូស្វរ

១៣- សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤- សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥- សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

## តារាងឧបសម្ព័ន្ធ ២

### កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

***

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតិអោយបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| ១ | សីតុណ្ហភាព | °C | < ៤៥ | < ៤៥ |
| ២ | pH | | ៦-៩ | ៥-៩ |
| ៣ | $BOD_5$ | mg/l | < ៣០ | < ៨០ |
| ៤ | COD | mg/l | <៥.០ | <១០០ |
| ៥ | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <០៦ | <១២០ |
| ៦ | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <១០០០ | <២០០០ |
| ៧ | ប្រេង ឬខ្លាញ់ | mg/l | < ៥.០ | < ១៥ |
| ៨ | សាប៊ូ | mg/l | < ៥.០ | < ១៥ |
| ៩ | ផេណុល | mg/l | < ០,១ | <១.២ |
| ១០ | នីត្រាត | mg/l | < ១០ | < ២០ |
| ១១ | ក្លរក្នុងទំរង់គេមី | mg/l | <១.០ | <២.០ |
| ១២ | ក្លរជាអ៊ីយ៉ុង | mg/l | <៥០០ | <៧០០ |
| ១៣ | ស៊ុលផាត | mg/l | <៣០០ | <៥០០ |
| ១៤ | ស៊ុលហ្វីត | mg/l | <០.២ | <១.០ |
| ១៥ | ផូស្វាត | mg/l | <៣.០ | <៦.០ |
| ១៦ | ស៊ីយ៉ានីត ( $CN^{1}$ ) | mg/l | <០.២ | <១.៥ |
| ១៧ | បារ្យ៉ូម ( Ba ) | mg/l | <៤.០ | <៧.០ |
| ១៨ | អាសេនិច ( As ) | mg/l | <០.១០ | <១.០ |
| ១៩ | សំណប៉ាហាំង ( Sn ) | mg/l | <២.០ | <៨.០ |
| ២០ | ដែក ( Fe ) | mg/l | <១.០ | <២០ |
| ២១ | បរ ( B ) | mg/l | <១.០ | <៥.០ |

| | | | | |
|---|---|---|---|---|
| ២២ | ម៉ង់កាណែស ( Mn ) | mg/l | <១.០ | <៥.០ |
| ២៣ | កាត់ម្យ៉ូម ( Cd ) | mg/l | <០.១ | <០.៥ |
| ២៤ | ក្រូម $( Cr)^{+៣}$ | mg/l | <០.២ | <១.០ |
| ២៥ | ក្រូម $( Cr)^{+៦}$ | mg/l | <០.០៥ | <០.៥ |
| ២៦ | ទង់ដែង ( Cu ) | mg/l | <០.២ | <១.០ |
| ២៧ | សំណ ( Pb ) | mg/l | <០.១ | <១.០ |
| ២៨ | បារត ( Hg ) | mg/l | <០.០០២ | <០.០៥ |
| ២៩ | នីកែល ( Ni ) | mg/l | <០.២ | <១.០ |
| ៣០ | សេលេញ៉ូម ( Se ) | mg/l | <០.០៥ | <០.៥ |
| ៣១ | ប្រាក់ ( Ag ) | mg/l | <០.១ | <០.៥ |
| ៣២ | ស័ង្កសី ( Zn ) | mg/l | <១.០ | <៣.០ |
| ៣៣ | ម៉ូលីបដែន (M0) | mg/l | <០.១ | <១.០ |
| ៣៤ | អាម៉ូញាក់ ( $NH_3$ ) | mg/l | <៥.០ | <៧.០ |
| ៣៥ | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | <២.០ | <១.០ |
| ៣៦ | ប៉ូលីក្លរ ប៊ីផេនិល ( PCB ) | mg/l | <០.០០៣ | <០.០០៣ |
| ៣៧ | កាល់ស្យូម ( Ca ) | mg/l | <១៥០ | <២០០ |
| ៣៨ | ម៉ាញេស្យូម ( Mg ) | mg/l | <១៥០ | <២០០ |
| ៣៩ | កាបូនតេត្រាក្លរ | mg/l | < ៣ | < ៣ |
| ៤០ | ម៉ិចសាក្លរបង់សែន | mg/l | < ២ | < ២ |
| ៤១ | ដេដេតេ | mg/l | <១,៣ | <១,៣ |
| ៤២ | អង់ឌ្រីន | mg/l | <០,០១ | <០,០១ |
| ៤៣ | ឌីអលឌ្រីន | mg/l | <០,០១ | <០,០១ |
| ៤៤ | អេនឌ្រីន | mg/l | <០,០១ | <០,០១ |
| ៤៥ | អ៊ីសូឌ្រីន | mg/l | <០,០១ | <០,០១ |
| ៤៦ | ពែក្លរអេទីឡែន | mg/l | < ២,៥ | < ២,៥ |
| ៤៧ | ម៉ិចសាក្លរប៉ុយតាឌីអែន | mg/l | < ៣ | < ៣ |
| ៤៨ | ក្លរហ្វូម | mg/l | < ១ | < ១ |
| ៤៩ | ១,២ឌីក្លរអេទីឡែន | mg/l | <២,៥ | <២,៥ |
| ៥០ | ទ្រីក្លរអេទីឡែន | mg/l | < ១ | < ១ |

| | | | | |
|---|---|---|---|---|
| ៥១ | ទ្រីក្លរូបង់សែន | mg/l | < ២ | < ២ |
| ៥២ | អ៊ិចសាក្លរូស៊ីក្លូអ៊ិចសែន | mg/l | < ២ | < ២ |

កំណត់សំគាល់ ៖ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវសហការរៀបចំកំរិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

## តារាងឧបសម្ព័ន្ធ ៣

### ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| ១ | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី ១ |
| ២ | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី ១ |
| ៣ | -ទីតាំងកែច្នៃផលនេសាទ | ទី ១ |
| ៤ | -ទីតាំងក្លាសេ និងបង្កក | ទី ១ |
| ៥ | -ទីតាំងផលិតម្សៅមី | ទី ១ |
| ៦ | -ទីតាំងផលិតស្ករស | ទី ១ |
| ៧ | -ទីតាំងផលិតទឹកស្អុត | ទី ១ |
| ៨ | -ទីតាំងផលិតសួនរបស់ប្រើប្រាស់ពីដី | ទី ១ |
| ៩ | -ទីតាំងផលិតកេសដ្ឋះ និងស្រាបៀរ | ទី ១ |
| ១០ | -ទីតាំងផលិតអាល់កុល និងស្រា | ទី ១ |
| ១១ | -ទីតាំងផលិតចំណីសត្វ | ទី ១ |
| ១២ | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី ១ |
| ១៣ | -ទីតាំងផលិតដំបែ និងមេស្រា | ទី ១ |
| ១៤ | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី ១ |
| ១៥ | -ទីតាំងផលិតបារី | ទី ១ |
| ១៦ | -ទីតាំងកាត់ដេរគ្មានក្រឡុកជ្រលក់ | ទី ១ |
| ១៧ | -សណ្ឋាគារ | ទី ១ |
| ១៨ | -ភោជនីយដ្ឋាន | ទី ១ |
| ១៩ | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី ១ |

| | | |
|---|---|---|
| ២០ | -ទីតាំងសត្តឃាត | ទី ១ |
| ២១ | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី ១ |
| ២២ | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី ១ |
| ២៣ | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី ១ |
| ២៤ | -ទីតាំងផលិតរបស់ផ្លាស្ទិក កៅស៊ូកង់ | ទី ១ |
| ២៥ | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី ១ |
| ២៦ | -ទីតាំងផលិតជ័រកាវ | ទី ១ |
| ២៧ | -ទីតាំងបង្អុក និងកែច្នៃជ័រកៅស៊ូ | ទី ១ |
| ២៨ | -ទីតាំងផលិតកែវ ដប | ទី ១ |
| ២៩ | -ទីតាំងផលិតស៊ីម៉ងត៍ | ទី ១ |
| ៣០ | -ការដ្ឋានយកថ្ម | ទី ១ |
| ៣១ | -ការដ្ឋានយកខ្សាច់ | ទី ១ |
| ៣២ | -ទីតាំងផលិតក្តារបន្ទះ | ទី ១ |
| ៣៣ | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី ១ |
| ៣៤ | -ទីតាំង លាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី ១ |
| ៣៥ | -នាវាដឹកសារធាតុរាវ | ទី ២ |
| ៣៦ | -ទីតាំងផលិតអាសេទីឡែន | ទី ២ |
| ៣៧ | -ទីតាំងផលិតសំលាប់ស្បែក | ទី ២ |
| ៣៨ | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី ២ |
| ៣៩ | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី ២ |
| ៤០ | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី ២ |
| ៤១ | -ទីតាំងគំបាញ់ រំជ្រលក់ពណ៌ | ទី ២ |
| ៤២ | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី ២ |
| ៤៣ | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី ២ |
| ៤៤ | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី ២ |
| ៤៥ | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី ២ |
| ៤៦ | -ទីតាំងផលិតថ្នាំពិល អាគុយ | ទី ២ |
| ៤៧ | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី ២ |
| ៤៨ | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី ២ |

| | | |
|---|---|---|
| ៤៩ | -ទីតាំងផលិតជ័រក្រាលថ្នល់ | ទី ២ |
| ៥០ | -ទីតាំងផលិតកញ្ចក់ធំ និងថ្នាំលាបកញ្ចក់ | ទី ២ |
| ៥១ | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី ២ |
| ៥២ | -ទីតាំងផលិតអ៊ីសូរ៉េ | ទី ២ |
| ៥៣ | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់ផ្សេង | ទី ២ |
| ៥៤ | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី ២ |
| ៥៥ | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី ២ |
| ៥៦ | -ទីតាំងផលិតដែក និងដែកថែប | ទី ២ |
| ៥៧ | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី ២ |
| ៥៨ | -ទីតាំងផលិតរបស់របរលោហៈ | ទី ២ |
| ៥៩ | -ទីតាំងក្លូម៉េរបស់លោហៈធាតុដែលមិនមែនដែក | ទី ២ |
| ៦០ | -ទីតាំងដុត ឬកែច្នៃសំណល់រឹង | ទី ២ |
| ៦១ | -ទីតាំងប្រព្រឹត្តកម្មសំអាតជី | ទី ២ |
| ៦២ | -ទីតាំងកែច្នៃសំណល់ប្រេង | ទី ២ |
| ៦៣ | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី ២ |
| ៦៤ | -មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី ២ |
| ៦៥ | -រោងចក្រអគ្គិសនី | ទី ២ |
| ៦៦ | -ទីតាំងកែច្នៃឈើ | ទី ២ |
| ៦៧ | -ការដ្ឋានស្រែបង្កា | ទី ២ |

## តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក

១- <u>សំរាប់ទន្លេ</u>

| ល.រ | ប៉ារ៉ាម៉ែត្រ | ឯកតា | កំរិតស្តង់ដារ |
|---|---|---|---|
| ១ | PH | | ៦,៥-៨,៥ |
| ២ | $BOD_5$ | mg /l | ១-១០ |
| ៣ | សារធាតុរឹងអណ្តែតក្នុងទឹក ( SS ) | mg /l | ២៥-១០០ |
| ៤ | កំរិតរលាយអុកស៊ីសែន ( DO ) | mg /l | ៧,៥-២,០ |
| ៥ | កូលីហ្វម ( Coliform ) | mg /l | < ៥០០០ |

២-សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| ១ | PH | | ៦,៥-៨,៥ |
| ២ | COD | mg /l | ១-៨ |
| ៣ | កាកសំណល់រឹងអណ្តែតក្នុងទឹក ( SS ) | mg /l | ១-១៥ |
| ៤ | កំរិតរលាយអុកស៊ីសែន ( DO ) | mg /l | ៧,៥-២,០ |
| ៥ | កូលីហ្វម ( Coliform ) | MPN/100ml | < ១០០០ |
| ៦ | អាសូតសរុប ( Total Nitrogen ) | mg /l | ០,១-០,៦ |
| ៧ | ផូស្វ័រសរុប ( Total Phosphorus ) | mg /l | 0,005-0,05 |

៣-សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| ១ | PH | | ៧,០-៨,៣ |
| ២ | COD | mg /l | ២-៨ |
| ៣ | កំរិតរលាយអុកស៊ីសែន ( DO ) | mg /l | ៧,៥-២,០ |
| ៤ | កូលីហ្វម ( Coliform ) | MPN/100ml | <១០០០ |
| ៥ | កាកសារធាតុប្រេង (Oil content ) | mg /l | ០ |
| ៦ | អាសូតសរុប ( Total Nitrogen ) | mg /l | ០,២-១,០ |
| ៧ | ផូស្វ័រសរុប ( Total Phosphorus ) | mg /l | 0,02-0,09 |

### តារាងឧបសម្ព័ន្ធ ៥

### កំរិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

### សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| ១ | កាបូនតេត្រាក្លរួ | ug/l | < ១២ |
| ២ | អ៊ិចសាក្លរ៉ូបង់សែន | ug/l | < ០,០៣ |
| ៣ | ដេដេតេ | ug/l | < ១០ |
| ៤ | អង់ឌ្រីន | ug/l | < ០,០១ |
| ៥ | ឌីអលឌ្រីន | ug/l | < ០,០១ |
| ៦ | អេនឌ្រីន | ug/l | < ០,០០៥ |

| | | | |
|---|---|---|---|
| ៧ | អ៊ិសូទ្រីន | ug/l | < ០,០០៥ |
| ៨ | ពែក្លរអេទីឡែន | ug/l | < ១០ |
| ៩ | អ៊ិចសាក្លរប៊ុយតាឌីអែន | ug/l | < ០,១ |
| ១០ | ក្លរហ្វម | ug/l | <១២ |
| ១១ | ១,២ឌីក្លរអេទីឡែន | ug/l | < ១០ |
| ១២ | ទ្រីក្លរអេទីឡែន | ug/l | < ១០ |
| ១៣ | ទ្រីក្លរបង់សែន | ug/l | < ០,៤ |
| ១៤ | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | ug/l | <០,០៥ |
| ១៥ | បង់សែន | ug/l | < ១០ |
| ១៦ | តេត្រាក្លរអេទីឡែន | ug/l | < ១០ |
| ១៧ | កាត់ម្ញូម | ug/l | < ១ |
| ១៨ | បារតសរុប | ug/l | <០,៥ |
| ១៩ | បារតសរីរាង្គ | ug/l | ០ |
| ២០ | សំណ | ug/l | < ១០ |
| ២១ | ក្រូមវ៉ាឡង់ ៦ | ug/l | <៥០ |
| ២២ | អាសេនិច | ug/l | <១០ |
| ២៣ | សេលេញ៉ូម | ug/l | <១០ |
| ២៤ | ប៉ូលីក្លរ ប៊ីផេនីល ( PCB ) | ug/l | ០ |
| ២៥ | ស៊ីអានីត ( CN ) | ug/l | <០,០០៥ |

★ ★ ★

## អនុក្រឹត្យលេខ ៩០ អនក្រ.តត
## ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សំរេច**

**មាត្រា ១ .-** លោក **ឈួន ថន** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ត្រូវបានផ្ទេរភារកិច្ចមកជាសាកលវិទ្យាធិការរងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩១ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សំរេច**

**មាត្រា ១ .-** តែងតាំងលោកស្រី **ម៉ិញ កុសនី** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៩២ អនក្រ.តត

## ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការកែប្រែមាត្រា២ នៃអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីរបៀប របប និងការរៀបចំការបោះឆ្នោត សភាពាណិជ្ជកម្ម
- តាមរបាយការណ៍របស់គណៈកម្មការរៀបចំបោះឆ្នោតសភាពាណិជ្ជកម្ម ដែលប្រកាសលទ្ធផលជាប់ឆ្នោត នៃសមាជិកសភាពាណិជ្ជកម្ម កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១ .** _ រំសាយសមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលបានបោះឆ្នោតជ្រើសតាំង កាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩៥ ចាប់ពីថ្ងៃទី២៤ ខែមិនា ឆ្នាំ១៩៩៩តទៅ ។

**មាត្រា ២ .** _ ទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ចំនួន ៣៦ រូប ដែលបែងចែកតាមប្រភេទអាជីវកម្ម មានដូចខាងក្រោម ៖

### ប្រភេទពាណិជ្ជកម្ម

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | ថេង ប៊ុនម៉ា | ៤-លោកឧកញ៉ា | ម៉ុន ឈុយស្រីម |
| ២-លោក | លឹម ហេង | ៥-លោក | ឡាំ ឃៀង |

| | | | |
|---|---|---|---|
| ៥-លោកឧកញ៉ា | សុខ គង់ | ៩-លោកឧកញ៉ា | ម៉ែន សារុន |
| ៦-លោក | តែ តាំងប៉ះ | ១០-លោកឧកញ៉ា | អ៊ុំ ម៉ុនហ៊ួទ |
| ៧-លោកជំទាវ | កែវ ម៉ាលី | ១១-លោក | ភួន ខេមរា |
| ៨-លោក | លឹម ចាន់ឌី | ១២-លោកឧកញ៉ា | គិត ចៀង |

ប្រភេទឧស្សាហកម្ម សិប្បកម្ម

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | គង់ ទ្រីទ | ៧-លោក | ហាន់ ឃៀង |
| ២-លោក | ឡាយ ម៉េងស៊ុន | ៨-លោក | គឹម ឡុង |
| ៣-លោក | គឹម ឈាន | ៩-លោក | ស៊ិន សុខណា |
| ៤-លោក | សេង ឆាយអ៊ុំ | ១០-លោក | ផ្លុង ឆុំ |
| ៥-លោកជំទាវ | តាន់ ផល្លី | ១១-លោកឧកញ៉ា | ឡាវ ម៉េងឃីន |
| ៦-លោកស្រី | ហង់ គីលី | ១២-លោក | ឡុច សារ៉េត |

ប្រភេទសេវាកម្ម និងវិជ្ជាជីវៈសេរី

| | | | |
|---|---|---|---|
| ១-លោកឧកញ៉ា | ស៊ិន សុខា | ៤-លោកឧកញ៉ា | គិត ម៉េង |
| ២-លោក | ចាន់ ថែន | ៥-លោក | ជាង សេង |
| ៣-លោក | ស្វាយ ទុន្ធី | ៦-លោកស្រី | សរ សុគន្ធា |

ប្រភេទកសិកម្ម

| | | | |
|---|---|---|---|
| ១-លោក | លី សារឿន | ៤-លោក | អ៊ុក ឃុន |
| ២-លោក | តឹក ឌុំយ | ៥-លោក | លី គួយ |
| ៣-លោក | កែវ មាស | ៦-លោក | ម៉ែន សុជាតិ |

**មាត្រា ៣ ._** ទទួលស្គាល់ លោក ឧកញ៉ា សុខ គង់ ជាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

**មាត្រា ៤ ._** ទទួលស្គាល់ លោកឧកញ៉ា ថេង ម៉ុនអាំ ជាប្រធានកិត្តិយស នៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ។

**មាត្រា ៥ ._** បង្កើតការិយាល័យប្រតិបត្តិការមួយរបស់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលមានសមាសភាពសំរាប់ដឹកនាំ និង គ្រប់គ្រង ដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោកឧកញ៉ា | សុខ គង់ | ជាប្រធាន |
| ២-លោក | ស៊ិន សុខណា | ជាអនុប្រធាន |
| ៣-លោក | តែ តាំងប៉ះ | ជាហិរញ្ញិក |
| ៤-លោក | លឹម ហេង | ជាហិរញ្ញិករង |
| ៥-លោកជំទាវ | ចាន់ ថែន | ជាលេខាធិការ |
| ៦-លោកស្រី | សរ សុគន្ធា | ជាលេខាធិការរង ។ |

**មាត្រា ៦ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និង សាមីខ្លួន ដែលមានចែងក្នុង មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៣ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១ .**_ តែងតាំងលោកស្រី **ស្រី ថាមរុន្ត** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អគ្គនាយករង** ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៩៨ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ ._** តែងតាំងលោក ម៉ៅញ សំអាន ជា ប្រធាននាយកដ្ឋានពិធីការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២ ._** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៩៥ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១ ._** តែងតាំងលោក **ស៊ិន យិន** ជា ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារតំកល់ឯកសារ និង កិច្ចការសមាគមសង្គហៈសង្គម នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៦ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១ .-** តែងតាំងលោកស្រី តាន់ ធានី ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកការងារសរុបរបាយការណ៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៧ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ ._ តែងតាំងលោកស្រី ឆាយ ចាន់ឡឿន បច្ចុប្បន្នជា អនុប្រធាននាយកដ្ឋានបុគ្គលិក ជាប្រធាននាយកដ្ឋាន សេវាកម្មកុំព្យូទ័រ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៨ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ ._ តែងតាំងលោក **លឹម សំកុល** ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## អនុក្រឹត្យលេខ ៤៩ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

### សំរេច

**មាត្រា ១ .**_ តែងតាំងលោក **ខៀវ ថវិកា** ជាប្រធាននាយកដ្ឋានពត៌មាននិងសារគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ២៦ សសរ
## ស្តីពីការបង្កើតគណៈកម្មការចំរុះដើម្បីដោះស្រាយបញ្ហាអ្នកស្លាក់នៅក្នុងអន្តេវាសិកដ្ឋានពេទ្យ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសំរេចលេខ២៣/សសរ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាអន្តេវាសិកដ្ឋានពេទ្យ
- យោងតាមការចាំបាច់

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះដើម្បីដោះស្រាយបញ្ហាអ្នកស្នាក់នៅក្នុងអន្តេវាសិកដ្ឋានពេទ្យ ដែលមានសមាសភាពដូចតទៅ ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ម៉ុន អ៊ុយ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២-ឯកឧត្តម | ទ៉ី គឹមយ៉ោ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ជាអនុប្រធាន |
| ៣-លោក | មួន លីមហេង | ប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច | សមាជិក |
| ៤-លោក | ខឹម ពិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-លោក | ជួ គឹមឡេង | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស | សមាជិក |
| ៦-លោក | ម៉ម ប៊ុន | ប្រធានស្តីទីនាយកដ្ឋានហិរញ្ញកិច្ចក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក | ស៊ាន មូរ៉ាត | មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-លោក | គង់ សារ៉ាន់ | ស្នងការរងនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៩-លោកវេជ្ជបណ្ឌិត | យក់ សុផាន់ណា | ព្រឹទ្ធបុរសមហាវិទ្យាល័យវេជ្ជសាស្ត្រ | សមាជិក |
| ១០-លោក | អ៊ឹម ជុំ | ប្រធាននាយកដ្ឋានអន្តេវាសិកដ្ឋានពេទ្យ | សមាជិក |
| ១១-លោក | នុយ ចំរើន | អគ្គានុរក្សសកលវិទ្យាល័យ វិទ្យាសាស្ត្រ សុខាភិបាល | សមាជិក |
| ១២-លោក | ម៉ក់ ចាន់ធី | តំណាងនិស្សិតអន្តេវាសិកដ្ឋានពេទ្យ | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ៖

- ដោះស្រាយអ្នកស្នាក់នៅក្នុងអន្តេវាសិកដ្ឋានពេទ្យ ដើម្បីយកទីតាំងនេះរៀបចំជាទីកន្លែងធ្វើការរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
- លើកវិធានការ និងសំណូមពរដោះស្រាយ ព្រមទាំងធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** សេចក្តីសំរេចណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល រាជធានីភ្នំពេញ សកលវិទ្យាធិការ នៃសកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

★★★

# សេចក្តីសំរេចលេខ ២៧ សសរ

រាជធានីភ្នំពេញ ,ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩

## ស្តីពីការ បញ្ចប់សុពលភាព លិខិតអនុញ្ញាតយកអាវុធតាមខ្លួន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ
- ដើម្បីធានាស្ថិរភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

## សំរេច

ប្រការ ១ : ត្រូវបានបញ្ចប់សុពលភាពលិខិតអនុញ្ញាតយកអាវុធតាមខ្លួន ចេញអោយដោយអាជ្ញាធរណាក្តីក្រសួងស្ថាប័ន ឬ មន្ត្រីណាក្តី ក្រៅពីល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា ៨ មាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ។

ប្រការ ២ : ជនណាប្រព្រឹត្តល្មើសនឹងប្រការ ១ នៃសេចក្តីសំរេចនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ២ និង មាត្រា ៥ នៃ ច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ញាដែល ប្រកាសឲ្យប្រើដោយក្រឹត្យលេខ ១១ ក្រ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង ខេត្ត ក្រុង ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

រាជធានីភ្នំពេញ ,ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩

## សេចក្តីសម្រេចលេខ ២៨ សសរ

## ស្តីពីការ បង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ
- ដើម្បីធានាស្ថិរភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

## សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យ និង ដកហូតអាវុធជាតិផ្ទុះ

**ក-នៅរាជធានីភ្នំពេញរួមមានសមាសភាពដូចខាងក្រោម ÷**

| | |
|---|---|
| ១-ឯកឧត្តម ជា សុផារ៉ា | ជាប្រធាន |
| ២-ឯកឧត្តម មាស សុផា | ជាអនុប្រធាន |
| ៣-ឯកឧត្តម គីម សំណាង | ជាអនុប្រធាន |
| ៤-ឯកឧត្តម សៅ សុខា | ជាសមាជិក |
| ៥-លោកឧត្តមសេនីយ៍ យុន ឈុន្នី | ជាសមាជិក |

៦-លោកឧត្តមសេនីយ៍ អ៊ុក គឹមលេខ ជាសមាជិក
៧-លោកឧត្តមសេនីយ៍ នេត សាវឿន ជាសមាជិក
៨-លោកឧត្តមសេនីយ៍ ថោង លីម ជាសមាជិក

**ខ-នៅខេត្ត ក្រុងរួមមានសមាសភាពដូចខាងក្រោម ៖**

១-ប្រធានគណៈបញ្ជាការឯកភាពខេត្ត-ក្រុង ជាប្រធាន
២-មេបញ្ជាការយោធភូមិភាគ ជាអនុប្រធាន
៣-ស្នងការនគរបាលខេត្ត-ក្រុង ជាសមាជិក
៤-មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ជាសមាជិក
៥-មេបញ្ជាការកងរាជអាវុធហត្ថ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច និង សិទ្ធិដូចតទៅ ៖

១-ប្រើប្រាស់កម្លាំងយោធា នគរបាល អាវុធហត្ថ ដើម្បីសហការបើកកិច្ចប្រតិបត្តិការចល័ត ត្រួតពិនិត្យតាមដងផ្លូវនៅរាជធានីភ្នំពេញ ឬ ខេត្ត-ក្រុង ។

២-ដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលបានធ្វើចរាចរលើផ្លូវសាធារណៈក្នុងរាជធានីភ្នំពេញ ឬ ខេត្ត-ក្រុង ដែលបានកំណត់ក្នុងសេចក្តីសំរេចស្តីពីការបញ្ចប់សុពលភាពលិខិត អនុញ្ញាតយកអាវុធតាមខ្លួន ។

៣-ចាត់វិធានការ បង្ការនិងបង្ក្រាបការបាញ់ដោះសេរីនៅក្នុងរាជធានីភ្នំពេញ ឬ ខេត្ត-ក្រុង ។

**ប្រការ ៣ :** គណៈកម្មការនេះ ត្រូវប្រជុំតាមការកំណត់របស់ប្រធាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង ។

**ប្រការ ៤ :** គណៈកម្មការនេះ ត្រូវរាយការណ៍រៀងរាល់ថ្ងៃ ពីលទ្ធផលការងាររបស់ខ្លួន ជូនសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ និង អគ្គនាយកនគរបាលជាតិ ។

**ប្រការ ៥ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង ខេត្ត ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ស ខេង**

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ២៩ សសរ**

**ស្តីពីការ បង្កើតគណៈកម្មការស្រាវជ្រាវអំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតច្រកទ្វារព្រំដែនកម្ពុជា- ថៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- យោងតាមស្មារតីអង្គប្រជុំអន្តរក្រសួង នាថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវអំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម សូ ម៉ាត់ | អគ្គនាយកក្រសួងទេសចរណ៍ | ប្រធាន |
| ឧត្តមសេនីយ៍ទោ **ជា សាអ៊ាន** | មេបញ្ជាការរង កងទ័ពជើងគោកក្រសួង ការពារជាតិ | អនុប្រធាន |
| ៣-លោក **អភិបាលរងខេត្តព្រះវិហារ** | | សមាជិក |
| ៤-លោក **ហួន សារ៉ាង** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាសមាជិកអាជ្ញាធរជាតិ ទទួលបន្ទុកកិច្ច ការព្រំដែន | សមាជិក |
| ៥-លោក **នង នីនាង** | អនុប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-លោក **សំ សុផល** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៧-លោក **អួច ទ័ន** | ប្រធាននាយកដ្ឋានអភិរក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៨-លោក **ស៊ីរ កុសល** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

៩-លោក **សាន ផាន់នី** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

**ប្រការ ២ :** គណៈកម្មការសិក្សាស្រាវជ្រាវអំពីតំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទ ព្រះវិហារ មានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាអំពីរូបភាពនៃការគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ ដោយ ធានាបានសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ការពារបរិស្ថានធម្មជាតិ និងវប្បធម៌បេតិកភ័ណ្ឌប្រវត្តិសាស្ត្ររបស់ជាតិដោយ ឈរលើ :
- លក្ខណៈបច្ចេកទេសខាងវិស័យទេសចរណ៍
- ទិដ្ឋភាពច្បាប់
- ការគិតគូរដល់អធិបតេយ្យភាព និងបូរណភាពដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា ស្តីពីការ បញ្ហាព្រំដែន
- ស្មារតីសហប្រតិបត្តិការអោយបានល្អជាមួយប្រទេសថៃ ជាលក្ខណៈអន្តរជាតិ និងប្រទេស ជិតខាង
- ស្មារតីរក្សាការពារបេតិកភ័ណ្ឌជាប្រវត្តិសាស្ត្ររបស់ជាតិ និងជំនឿសាសនាអោយបាន ស្ថិតស្ថេរចិរកាល កុំអោយរងគ្រោះដោយសារការបំផ្លិចបំផ្លាញ
- ធានាសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់របៀបរៀបរយ
- ការគិតគូរពីរូបភាពគ្រប់គ្រងនិងរបៀបផ្ទេរពីការកាន់កាប់របស់កងទ័ពមកអ្នកគ្រប់គ្រងថ្មី។

**ប្រការ ៣ :** គណៈកម្មការនេះមានលេខាធិការដ្ឋាននៅក្រសួងទេសចរណ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង ទេសចរណ៍ ដើម្បីសំរួលការងារ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការសិក្សាស្រាវជ្រាវអំពីតំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទ ព្រះវិហារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** គណៈកម្មការនេះត្រូវរៀបចំតំរោងស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះ វិហារ មកអោយទីស្តីការគណៈរដ្ឋមន្ត្រីអោយបានឆាប់បំផុត ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីសំរេច ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងអភិបាលខេត្ត ព្រះវិហារ និងអស់លោកដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

## សេចក្ដីសំរេចលេខ ៣០ សសរ

## ស្ដីពីការបន្ថែមសមាសភាពក្នុងគណៈកម្មការដកហូតអាវុធជាតិផ្ទុះ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២/អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្ដីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញសេចក្ដីសំរេចលេខ ២៨/សសរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះ
- ដើម្បីធានាស្ថិរភាព សុវត្ថិភាព សណ្ដាប់ធ្នាប់សង្គម

## សំរេច

**ប្រការ ១ :** ត្រូវបានបន្ថែម ឯកឧត្ដម **ជា សារិន** , លោក **ហួត ឈាន** និងលោក **ឈិន ចំនួនណ៍** ជាសមាជិកក្នុងគណៈកម្មការដកហូតអាវុធជាតិផ្ទុះនៅរាជធានីភ្នំពេញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ខេត្ត-ក្រុង និង សាមីខ្លួន ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស ខេង**

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៣១ សសរ**

**ស្តីពីការបង្កើតគណៈកម្មការជួសជុលប៉ុរីកីឡា**

**រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការជួសជុលប៉ុរីកីឡាលេខ ១២៤ សសរ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើសុំផ្លាស់ប្តូរសមាសភាពគណៈកម្មការជួសជុលប៉ុរីកីឡាលេខ ១១៤៣ អយក.រប ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩ របស់ក្រសួងអប់រំ យុវជន និង កីឡា

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការជួសជុលប៉ុរីកីឡា ដែលមានសមាសភាពកែសំរួលដូចតទៅ :

១-ឯកឧត្តម **មី សាម៉ឺឌី** ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សហប្រធាន

២-ឯកឧត្តម **ម៉ុក ចន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជា សហប្រធានសមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ។

៣-ឯកឧត្តម**ម៉ុន ឌីយ** អគ្គហិរញ្ញិកនៃគណៈកម្មាធិការអូឡាំពិកកម្ពុជា អគ្គលេខាធិការ

៤-លោកជំទាវ **ស៊ិន ស៊ី** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី

៥-ឯកឧត្តម **ម៉ូ ជុំសេរី** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អគ្គហិរញ្ញិករង

៦-លោក **សូ សាមុត** អនុប្រធានទទួលបន្ទុកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា សមាជិក

៧-លោក **មាស សារិន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

៨-លោក **ជា ស៊ើន** ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋក្រសួងអប់រំ យុវជន និងកីឡា សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

- សិក្សាវាយតំលៃស្ថានភាពសំណង់ក្នុងប៉ុរីកីឡា និង លើកគំរោងជួសជុល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលអនុម័ត ។
- ពិភាក្សា សំរបសំរួលគំរោងទានសំរាប់ ប្រើប្រាស់ក្នុងការជួសជុលប៉ុរីកីឡា ជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន ។

- ពិភាក្សា សំរបសំរួលជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីជ្រើសរើសរកសហគ្រិន ដែលមានស្នាដៃល្អក្នុងការងារសំរាប់ជួលជុលបូរីកីឡា ។
- ត្រួតពិនិត្យដំណើរការជួសជុលបូរីកីឡា និង រាយការណ៍អំពីការងារសំរេចបាន ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មាការមួយចំនួន ដើម្បីជាជំនួយការងារ និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ។

ប្រការ ៤ : សមាជិករបស់គណៈកម្មាការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : រាល់បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹង សេចក្តីសំរេចនេះទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

រាជធានីភ្នំពេញ ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣២ សសរ
## ស្តីពីការបន្ថែមសមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយ បញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ០៧/សសរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- តាមសំណើរប្រធានគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

**សំរេច**

**ប្រការ ១ :** ត្រូវបានបន្ថែម សមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយបញ្ហាក្ងួជកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានរាយនាមដូចខាងក្រោម ៖

១-ឯកឧត្តម **ពៅ យ៉ាំងា** អនុរដ្ឋលេខាធិការ ក្រសួងពត៌មាន ជាសមាជិក

២-ឯកឧត្តម **អ៊ុំ ម៉ុនជឿន** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជាសមាជិក

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ខេត្ត-ក្រុង និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

[illegible]
ផ្ទះ ០០៦.១ ផ្លូវ ១មិថុនា

[illegible]

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល